ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-Jan-2020, 14:50
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen Harding CLARK
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ:

# សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យបដិសេធសារណារបស់ ដើមបណ្តឹងរដ្ឋប្បវេណី

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Brenda HOLLIS

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Megan HIRST

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន
Anta GUISSÉ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F50/1/1/2

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួលសំណើរបស់ ខៀវ សំផន សុំឱ្យបដិសេធសារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមសេចក្តីនាំណែអនុវត្តស្តីពីការដាក់ឯកសារ ("សំណើ")[1]។

## I. សាវតារ

1. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ ដោយបានសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយបានសម្រេចដាក់ទោស នួន ជា និង ខៀវ សំផន ឱ្យជាប់ពន្ធនាគារអស់មួយជីវិត[2]។ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងអំពីសាលក្រមដែលមានសម្អាងហេតុពេញលេញ ជាភាសាខ្មែរ អង់គ្លេស និងបារាំងនឹងចេញនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ("សាលក្រមអង្គជំនុំជម្រះសាលាដំបូង")[3]។

2. អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ថា រាល់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខត្រូវដាក់នៅមុនថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩[4]។ នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង[5]។ នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ

---

[1] សំណើរបស់ ខៀវ សំផន សុំឱ្យបដិសេធសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី(F50/1/1) ដោយអនុលោមតាមសេចក្តីណែនាំអនុវត្តដាក់ឯកសារ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F50/1/1/1 ("សំណើ")។

[2] *សូមមើលប្រៀបធៀបសំណុំរឿង* ០០២/០២ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/259.1 (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ទំព័រ ៣៨ (ជួរ ២៥) ដល់ ៤១ (ជួរ ១០)។

[3] អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ដោយសារសាលក្រមនេះពុំត្រូវបានដាក់ក្នុងម៉ោងធ្វើការជាផ្លូវការរបស់ អ.វ.ត.ក. ដូច្នេះសេចក្តីជូនដំណឹងនៃសាលក្រមនេះមានអានុភាពគិតចាប់ពីថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដាក់នោះ គឺចាប់ពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩។

[4] សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមទំព័រ និងពេលវេលាសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43 កថាខណ្ឌ ១៣។

[5] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៩ ឯកសារលេខ E465/2/1។

២០១៩ សហព្រះរាជអាជ្ញាបានដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន("សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")[6]។

3. នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ បន្ទាប់ពីបានទទួលការអនុញ្ញាតរយៈពេល ៣០ ថ្ងៃចាប់ពីការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើសំណើសុំបន្ថែមពេលវេលា[7] ខៀវ សំផន បានដាក់សារណាតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ("សារណាតបរបស់ ខៀវ សំផន")[8]។ នៅថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៩ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សារណាពាក់ព័ន្ធទៅនឹងសារណាតបរបស់ ខៀវ សំផន ("សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី")[9]។

4. នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សំណើសុំឱ្យបដិសេធសារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី[10]។

5. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពុំបានឆ្លើយតបឡើយ។

## II. សារណា

### *ដើមបណ្ដឹងរដ្ឋប្បវេណី*

6. នៅក្នុងសារណារបស់ខ្លួន(ត្រង់ចំណុចដែលស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការពិចារណាក្នុងការសម្រេចលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា) ដើមបណ្ដឹងរដ្ឋប្បវេណីបានឱ្យដឹងថា ពេលវេលា"មិនអំណោយ

---

[6] បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F50 ("សារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")។

[7] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F49 កថាខណ្ឌ ២៨ និង ៣៦។

[8] សារណាតបរបស់មេធាវីការពារក្ដីទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៩ ឯកសារលេខ F50/1 ("សារណាតរបស់មេធាវីការពារក្ដី ខៀវ សំផន")។

[9] សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F50/1/1 ("សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី") ជូនដំណឹងជាភាសាអង់គ្លេស និងខ្មែរនៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៩ និងបារាំងនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៩។

[10] សំណើ កថាខណ្ឌ ៩។

ផលក្នុងការដាក់សារណាតបទៅនឹងសារណារបស់ភាគីដទៃ"[11]។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានអះអាងថា សារណារបស់ខ្លួនគប្បីត្រូវបានអនុញ្ញាតដោយសារហេតុផលពីរចំណុចសំខាន់ៗ។ ទីមួយ សារណានោះដោះស្រាយតែលើបញ្ហាដែលប៉ះពាល់ដោយផ្ទាល់លើសិទ្ធិ និងអត្ថប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដូចជា ភាពអាចជឿជាក់ និងទុកចិត្តបាន និងការជាប់ពាក់ព័ន្ធជាមួយនឹងភស្តុតាងមួយចំនួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ទីពីរ សារណានោះពុំដោះស្រាយបញ្ហាដដែលៗ ដែលបានលើកឡើងនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាឡើយ[12]។ សហមេធាវីនាំមុខបានជំទាស់ទៅនឹងការកំណត់របស់ ខៀវ សំផន លើចរិតលក្ខណៈនៃភស្តុតាងរបស់ ឯម អឿន ថា កង្វះនូវភាពអាចជឿជាក់ និងទុកចិត្តបាន[13]។ ដោយបានកត់សម្គាល់លើអំណះអំណាងរបស់ ខៀវ សំផន ទាក់ទងទៅនឹងការកម្រិតវិសាលភាពនៃការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី ឯម អឿន ក្នុងសំណុំរឿង ០០២/០១ សហមេធាវីសុំរក្សាសិទ្ធិក្នុងការឆ្លើយតបនៅក្នុងបរិបទនៃបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន[14]។

### *សំណើរបស់ ខៀវ សំផន សុំឱ្យបដិសេធសារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី*

7. នៅក្នុងសំណើរបស់ខ្លួន ខៀវ សំផន បានអះអាងថា សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី"ដែលឆ្លើយតបទៅនឹងសារណាតប ជាក់ស្ដែង គឺជាការឆ្លើយតប"[15]។ មេធាវីការពារក្ដីបានលើកឡើងថា សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់ក្នុងរយៈពេល ១០ ថ្ងៃបន្ទាប់ពីការជូនដំណឹងនៃសារណាតប ហើយអង្គជំនុំជម្រះបានជូនដំណឹងភាគីថា ការឆ្លើយតបទៅនឹងសារណាតបនៃបណ្ដឹងសាទុក្ខនឹងត្រូវធ្វើឡើងតាមរយៈការលើកឡើងផ្ទាល់មាត់[16]។ មេធាវីការពារក្ដីសន្និដ្ឋានថា ដើមបណ្ដឹងរដ្ឋប្បវេណី ជាផ្លូវការពុំអាចត្រូវបានអនុញ្ញាតឱ្យដាក់សារណារបស់ខ្លួន ហើយបានស្នើសុំឱ្យអង្គជំនុំជម្រះបដិសេធសារណានេះ[17]។

---

[11] សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ១០។

[12] សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ៨។

[13] សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ១២។

[14] សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ១៣។

[15] សំណើ កថាខណ្ឌ ៤។

[16] សំណើ កថាខណ្ឌ ៥ ដល់ ៧។ សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F49 កថាខណ្ឌ ៣៦ អនុកថាខណ្ឌចុងក្រោយ។

[17] សំណើ កថាខណ្ឌ ៧ និង ៩។

## III. ច្បាប់ជាធរមាន

8. មាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តចែងថា "សារណាតបណាមួយទៅនឹងសំណើ ឬសារណា ត្រូវដាក់ជាមួយនឹងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ដែលប្រើប្រាស់ជាឯកសារយោងក្នុងរយៈពេល ១០(ដប់) ថ្ងៃនៃប្រតិទិនគិតចាប់ពីការជូនដំណឹងនៃឯកសារចំពោះភាគីត្រូវឆ្លើយតប"[18]។ មាត្រា ៨.៤ ចែងបន្ថែមទៀតថា "ការឆ្លើយតបទៅនឹងសារណាតប ត្រូវបានអនុញ្ញាតតែក្នុងករណីដែលពុំមានការដេញដោលត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ប៉ុណ្ណោះ ហើយការឆ្លើយតបនេះត្រូវដាក់ក្នុងរយៈពេលប្រាំថ្ងៃនៃប្រតិទិនគិតចាប់ពីថ្ងៃជូនដំណឹងនៃសារណាតបចំពោះភាគីត្រូវធ្វើការឆ្លើយតប"[19]។

9. យោងតាមវិធាន ៣៩(១) នៃវិធានផ្ទៃក្នុងចែងថា "រាល់កាលបរិច្ឆេទដែលបានកំណត់នៅក្នុង [...] សេចក្តីណែនាំអនុវត្តជាធរមាន និងក្នុងករណីសមស្រប សេចក្តីសម្រេចរបស់ចៅក្រម ត្រូវតែគោរពតាម។ ក្នុងករណីមិនគោរពតាមវិធានផ្ទៃក្នុងនេះ គឺនាំឱ្យកិច្ចដែលបានធ្វើនោះត្រូវចាត់ទុកជាអសុពលភាព"[20]។ វិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចតាមសំណើសុំរបស់ភាគីពាក់ព័ន្ធ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន"ទទួលស្គាល់ថា មានសុពលភាពចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយកាលបរិច្ឆេទដែលបានកំណត់នៅក្នុងវិធានផ្ទៃក្នុងនេះ ក្នុងករណីចាំបាច់ប្រសិនបើខ្លួនយល់ឃើញថា មានលក្ខណៈសមស្រប"[21]។ វិធានផ្ទៃក្នុងបានចែងបន្ថែមទៀតថា "កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក. ត្រូវតែមានយុត្តិធម៌ត្រូវគោរពគោលការណ៍ចំពោះមុខហើយត្រូវរក្សាតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"[22]។

## IV. ការពិភាក្សា

10. ជាការកត់សម្គាល់បឋម អង្គជំនុំជម្រះរំលឹកថា អង្គជំនុំជម្រះបានយល់ឃើញតាំងពីដំបូងថា ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិឆ្លើយតបទៅនឹងសារណារបស់មេធាវីការពារក្តី រួមទាំងនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីនៃបណ្តឹងសាទុក្ខ ដរាបណាសារណានោះ"ពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍ដែលប៉ះពាល់ដោយផ្ទាល់ ដល់សិទ្ធិ និងអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី" និង"ត្រូវជៀសភាពច្រំដែល

[18] សេចក្តីណែនាំអនុវត្ត មាត្រា ៨.៣។

[19] សេចក្តីណែនាំអនុវត្ត មាត្រា ៨.៤។

[20] វិធាន ៣៩(១) នៃវិធានផ្ទៃក្នុង។

[21] វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង។

[22] វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង។

និងភាពជាន់គ្នាជាមួយនឹងបញ្ហា ដែលបានលើកឡើងរួចមកហើយនៅក្នុងសារណាតបរបស់សហព្រះរាជអាជ្ញា”[23]។ នៅក្នុងបញ្ហាចំពោះមុខ អង្គជំនុំជម្រះជឿជាក់ថា អំណះអំណាងដែលមាននៅក្នុងសារណាតបរបស់ ខៀវ សំផន ប៉ះពាល់ដល់អត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីត្រង់ចំណុចដែលត្រូវជំទាស់ទៅនឹងភាពអាចជឿជាក់ និងទុកចិត្តបាននៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះជឿជាក់បន្ថែមទៀតថា ចំណុចជាក់លាក់ពីរទាក់ទងទៅនឹងការប្រើប្រាស់ភស្តុតាងរបស់ ឯម អឿន ដែលបានពិភាក្សាដោយសហមេធាវីនាំមុខ ពុំមានលក្ខណៈច្រំដែល និងជាន់គ្នាជាមួយនឹងសារណារបស់សហព្រះរាជអាជ្ញាឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាឃើញថា សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីគោរពតាមការកំហិតដូចបានលើកឡើងខាងលើ។

11. ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះរំលឹកបន្ថែមទៀតថា៖

> “ភាគីត្រូវដាក់សារណាជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គជំនុំជម្រះដែលមានសមត្ថកិច្ចរហូតដល់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ដូចមានចែងលម្អិតនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ជាការសមហេតុផល ការអនុញ្ញាតឱ្យដាក់សំណើសុំជាលាយលក្ខណ៍អក្សរ និងសារណាត្រូវរួមបញ្ចូលសិទ្ធិដាក់សារណាតប និងការឆ្លើយតបទៅនឹងសារណារបស់ភាគីដទៃទៀត ដែលស្របទៅនឹងគោលការណ៍នៃកិច្ចដំណើរការនីតិវិធីដេញដោលចំពោះមុខ”[24](សេចក្តីបញ្ជាក់បន្ថែម)។

---

[23] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F10/2 កថាខណ្ឌ ១៧៖ “កថាខណ្ឌនេះបញ្ជាក់ថា អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ដោយសារពុំមានភាពផ្ទុយគ្នាជាគោលការណ៍រវាងសិទ្ធិក្នុងការឆ្លើយតប និងគោលបំណងនៃការចូលរួមរបស់ជនរងគ្រោះ សិទ្ធិទាំងនេះត្រូវតែបកស្រាយឱ្យស្របជាមួយនឹងតួនាទីបន្ទាប់បន្សំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងតួនាទីរបស់សហព្រះរាជអាជ្ញា។ បន្ថែមលើនេះ ក្រោយពីបានពិចារណាលើតម្រូវការចាំបាច់ដើម្បីធានាបាននូវតុល្យភាពនៃកម្លាំងតទល់ និងក្តីបារម្ភពាក់ព័ន្ធនឹងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាពលើកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ការអនុវត្តន៍សិទ្ធិក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ត្រូវតែស្ថិតក្រោមការកម្រិត។ ដំបូង អំណះអំណាងដែលបានលើកឡើងនៅក្នុងសារណាតបនោះ ត្រូវតែពាក់ព័ន្ធទៅនឹងទង្វើករណ៍ដែលប៉ះពាល់ដោយផ្ទាល់ទៅលើសិទ្ធិ និងអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ បន្ទាប់មក សហមេធាវីនាំមុខត្រូវប្រឹងប្រែជៀសវាងភាពច្រំដែល និងការជាន់គ្នាជាមួយនឹងបញ្ហាដែលបានលើកឡើងរួចរាល់នៅក្នុងសារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។ ចុងបញ្ចប់ អង្គជំនុំជម្រះតុលាការកំពូលសម្រេចកំណត់កាលបរិច្ឆេទសម្រាប់ការដាក់សារណាតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ពីការជូនដំណឹងអំពីសារណាតបរបស់សហព្រះរាជអាជ្ញា ដូចបានបញ្ជាក់ខាងក្រោម”។

[24] សេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F10/2 កថាខណ្ឌ ១៤។

12. ទាក់ទងនឹងបញ្ហានេះ អង្គជំនុំជម្រះបានសង្កេតឃើញថា សហមេធាវីនាំមុខត្រឹមតែទទួលស្គាល់ថា ពេលវេលា និងការដាក់សារណានេះ មានលក្ខណៈ“ខុសពីធម្មតា”[25] និងថា “ពុំស្ថិតក្នុងក្របខ័ណ្ឌនៃការដាក់សារណាដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត”[26]។ អង្គជំនុំជម្រះបានកត់សម្គាល់ផងដែរថា ក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក. ពុំបានសម្របទៅតាមការដាក់សារណា“ខុសពីធម្មតា”នោះឡើយ។ អង្គជំនុំជម្រះពុំចាំបាច់ផ្តល់សំអាងហេតុ ឬការពន្យល់អំពីការដាក់សារណាដោយភាគីឡើយ និងបានយល់ឃើញថា សារណាដែលពុំបានដាក់ក្នុងក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក. ពុំអាចទទួលយកបាន។ ភាគីត្រូវជៀសវាងដាក់សារណាដែលមានលក្ខណៈពុំច្បាស់លាស់។

13. អង្គជំនុំជម្រះជូនដំណឹងថា ដើម្បីអត្ថប្រយោជន៍យុត្តិធម៌ សហមេធាវីនាំមុខអាចនឹងត្រូវបានអញ្ជើញលើកសារណាផ្ទាល់មាត់នៅពេលសវនាការបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ ដោយហេតុថា សិទ្ធិក្នុងការឆ្លើយតបអាចត្រូវបានអនុញ្ញាត។

14. សេចក្តីសម្រេចនេះពុំបានប៉ះពាល់ដល់ការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស ដែលជំនុំជម្រះលើសំណើរបស់ ខៀវ សំផន សុំប្តឹងជិតចិត្តចៅក្រមអង្គជំនុំជម្រះតុលាការកំពូលចំនួនប្រាំមួយរូប ដែលជំនុំជម្រះសំណុំរឿង ០០២/០១ ឡើយ។

## V. ផ្នែកសម្រេចសេចក្តី

15. យោងតាមសម្អាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល៖**

**សម្រេច**ទទួលយកលើសំណើនេះ

**បដិសេធ**សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០២០

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

[25] សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១០។

[26] សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៧។